# ខ្មែរ_អាមេរិកាំងនៅឡូវែលតវ៉ានៅសាលាក្រុង

**ដោយ ពិន សំខុន**

## Khmer Lowell Protested at City Hall - In English,
see page 28

**By Pin Samkhon**



ជាលើកដំបូងបង្អស់នៃប្រវត្តិក្រុងឡូវែលដែលក្រុមប្រឹក្សាសាលាក្រុងឡូវែលបានបោះឆ្នោតដើម្បីសហគមន៍ខ្មែរ-អាមេរិកាំងផ្ដល់"៨សម្លេងព្រម"នឹង"១សម្លេងអនុប្បវាទ"មិនទទួលបដិសណ្ឋារកិច្ចឧត្តមសេនីយ ហ៊ុន ម៉ាណែត នាយអគ្គសេនាធិការរងនៃកងយោធពលខេមរភូមិន្ទជាកូនប្រុសច្បងរបស់លោកនាយករដ្ឋមន្ត្រីយូរអង្វែង ហ៊ុន សែន ដែលត្រូវមកដល់នាឱកាសចូលឆ្នាំថ្ងៃទី១៦-១៧មេសានឹងមិនទទួលយកអំណោយ"រូបចម្លាក់ព្រះបាទជ័យវរ្ម័នទី៧"នាំមកដោយឧត្តមសេនីយដដែលនេះ។ ប្រជាពលរដ្ឋខ្មែរព្រមានជាង៣០០នាក់ បានចេញមកធ្វើការតវ៉ាយ៉ាងកុះករ

**តទៅទំព័រទី ១១**



តមកពីទំព័រទី ០១ ខ្មែរ-អាមេរិកាំងនៅឡូវែល...



ក្នុងកិច្ចប្រជុំប្រចាំសប្ដាហ៍ពេញអង្គរបស់គណកម្មការសាលាក្រុងឡូវែល៩រូប ទាមទារឱ្យរដ្ឋាភិបាលក្រុងឡូវែលធ្វើសេចក្ដីសម្រេចចិត្តចំពោះការទទួលបរិសណ្ឋារកិច្ចចំពោះលោកឧត្តមសេនីយ ហ៊ុន ម៉ាណែត កាលពីថ្ងៃទី២៨ មិនា ឆ្នាំ២០១៦។

ក្រុមបដិបក្ខ២ក្រុមបានមកបញ្ចេញមតិផ្ទុយគ្នាក្រុមទី១មានគ្នាប្រមាណ១០-២០នាក់គាំទ្រវត្តមានឧត្តមសេនីយ ហ៊ុន ម៉ាណែត សុំឱ្យសាលាក្រុងឡូវែលទទួលបដិសណ្ឋារកិច្ចនឹងឱ្យទទួលយករូបចម្លាក់ដែលកំពុងតែធ្វើដំណើរមកពីប្រទេសកម្ពុជាដោយមានបដារជាច្រើនបង្ហាញពីមតិរបស់ខ្លួនផង ក្រុមនេះដឹកនាំដោយគ្រួសារលោកអគ្គកុងស៊ុល អ៊ូ សុវណ្ណ ដែលមិនបានមកចូលរួមទេ មកតែភរិយា ហើយនឹងគ្រួសារលោកតុលា យុទ្ធ។ ក្រុមមួយទៀតប្រឆាំងនឹងវត្តមានកូនលោក ហ៊ុន សែន មានគ្នាប្រមាណ៣០០នាក់ លើកបដារជាច្រើនបញ្ចេញមតិពីសកម្មភាពកូនលោក ហ៊ុន សែន នឹងឪពុករបស់គេកំពុងធ្វើនយោបាយអមនុស្សធម៌ផ្ដាច់ការនិយមនៅកម្ពុជានឹងបំណងពង្រីកវប្បធម៌នោះមកសហរដ្ឋអាមេរិក។ ខ្មែរ-អាមេរិកាំងជាង២០នាក់បានចុះឈ្មោះឡើងមកនិយាយពន្យល់អង្គប្រជុំក្រុមប្រឹក្សាក្រុងម្នាក់ម្ដងៗដែលនេះជាលើកដំបូងបង្អស់ដែលអ្នកគ្រប់គ្រងក្រុងឡូវែលបានយល់ពីបណ្ដាប្រជាពលរដ្ឋរបស់ខ្លួនបានច្រើនជាអតិមរមា។ អ្នកឡើងនិយាយមានជាអាទិ តុលា យុទ្ធ តំណាងឱ្យអ្នកគាំទ្រឱ្យ ហ៊ុន ម៉ាណែត មកឡូវែល រីឯខាងអ្នកមិនគាំទ្រមានជាអាទិ ខេមរា ខៃ ជាបេក្ខជនតំណាងរដ្ឋមកពីគណបក្សសាធារណរដ្ឋ អាដាមព្រិល ដំណាងពាណិជ្ជករ ចម្បា ប៉ាង ដំណាងឱ្យក្រុងខ្មែរ អ៊ុង ឫទ្ធី នឹង វ៉ាស្នា នួន ដែលជាអតីតសមាជិកក្រុមប្រឹក្សាក្រុងឡូវែលបានឡើងមកថ្លែងការពារគំនិតយោបល់តំណាងឱ្យក្រុមរៀងៗខ្លួនបានយ៉ាងច្បាស់លាស់ ។ អង្គប្រជុំប្រកបដោយអារម្មណ៍ចងចាំនូវព្រឹត្តិការណ៍នយោបាយចាស់នឹងថ្មីពីកម្ពុជាបានឆ្លើយតបទៅនឹងវាគ្មិនដែលឡើងមកថ្លែងការណ៍ ដោយទះដៃអបអរសាទរ ឬក៏ស្រែកចំអកទៅនឹងប្រយោគដែលប៉ះពាល់ដល់អារម្មណ៍ខ្លួនយ៉ាងខ្លាំងក្លាផ្អើលពេញសាលាក្រុងដែលបណ្ដាលឱ្យមានការព្រមានម្ដងម្កាលដោយអភិបាលក្រុងជាប្រធាននៃអង្គប្រជុំ។ បច្ចុប្បន្នអភិបាលក្រុង អេដវ៉ិត ខេណ្ណីឌី ឋិតនៅជាអជ្ញាកណ្ដាល ប៉ុន្តែអតីតអភិបាលក្រុង អេលីយ៉ុត រ៉ែតនីយ ដែលជាហត្ថលេខីនៃទីក្រុងភ្លោះភ្នំពេញ-ឡូវែល នឹង រីតា មើសៀ សមាជិកក្រុមប្រឹក្សាក្រុងដ៏មានប្រជាប្រិយភាពបំផុតបានផ្ដល់នូវអារម្មណ៍ផ្លាស់ប្ដូរមកគាំទ្រការសម្ដែងមតិដ៏ក្ដុកក្ដួលរបស់ពលរដ្ឋរងគ្រោះភាគច្រើនជាអតីតជនភៀសខ្លួនរស់នៅតំបន់របស់ខ្លួន។ ព្រឹត្តិការណ៍ដូចគ្នានេះ បានកើតកាលពី២សប្ដាហ៍មុននៅសហគមន៍ខ្មែរ-អាមេរិកាំងនៅរដ្ឋកាលីហ្វ័រញ៉ានាទីក្រុងឡុងប៊ិច ក៏បានបើកទំព័រប្រវត្តិសាស្ត្រថ្មីសម្រាប់ប្រជាពលរដ្ឋខ្មែរ-អាមេរិកាំងនៅទីនោះដែរ តែការតវ៉ានេះមិនមែនជាលើកទី១ទេ។







ព្រឹត្តិការណ៍ថ្ងៃទី២៨មិនានៅឡូវែលនេះបានកំណត់នូវការអនុវត្តន៍ដំណើរការនៃលទ្ធិប្រជាធិបតេយ្យយ៉ាងពេញទំហឹងរបស់សហគមន៍ខ្មែរ-អាមេរិកាំងដែលធ្វើឱ្យមានការភ្ញាក់ផ្អើលដល់សហគមន៍ខ្មែរឯទៀតៗនៅជុំវិញពិភពលោក សារព័ត៌មានក្នុងតំបន់ មានវិទ្យុ "WCAP" កាសែត "ឡូសាន់" ឬក្រៅតំបន់បានមកយកការណ៍ទៅផ្សព្វផ្សាយជាសាធារណនឹងជាព័ត៌មានក្ដៅ ដូចជា "អិនភីអរ NPR" ឬ "អេប៊ីស៊ី ABC" វិទ្យុ "វីអូអេ VOA" នឹង "អាស៊ីសេរី RFA" ជាដើម រួមទាំងកាសែត "ឌឹខេមបូឌាដេលិ TheCambodia Daily" នៅកម្ពុជា ក៏ចុះផ្សាយព័ត៌មាននេះយ៉ាងពិស្ដារដែរ។ ដំណើរការណ៍នេះបាននាំឱ្យសហគមន៍មានកម្លាំងកំហែងឡើងខ្លាំងជាងមុនដោយការសម្ដែងមតិមូលមាត់គ្នា ដើម្បីកសាងសង្គមដែលខ្លួនឯងរស់នៅឱ្យបានរឹតតែប្រសើរឡើង ។ ការទាមទារនេះអមដោយមានសេចក្ដីសម្រេចប្រើ "ថ្នាំខ្លាំង" ដោយសាលាក្រុងអាមេរិកាំងជាលើកដំបូងនេះ គ្រាន់តែជាសញ្ញា "ចាប់ផ្ដើម" តែប៉ុណ្ណោះ ដែលនឹងមានឥទ្ធិពលនៅក្នុងតំបន់ផង នឹងជួយលើកទឹកចិត្តដល់សកម្មជននៅកម្ពុជាពីសកម្មភាពត្រឹមត្រូវដើម្បីប្រទេសរបស់ខ្លួនទៀតផង។















តើវានឹងផ្ដើមអ្វីខ្លះ? បញ្ហាជាច្រើនដែលមេដឹកនាំសហគមន៍បំរុងនឹងប្រឈមមុខដោះស្រាយជាបន្ត គឺសំអាតចរន្តអ្នកយកមុខមាត់ជាមួយ "ក្រុងភ្នំពេញ" ដោយយកក្រុងឡូវែលទៅប្រើជាឈ្នាន់។ នៅមានការជជែកគ្នាថែមទៀត ពីអ្នកដែលបានបង្កឱ្យមានភាពស្មុគស្មាញពេញសហគមន៍ដោយយកអង្គការ ឬសមាគមមិនរកកម្រៃដែលខ្លួនកាន់កាប់ទៅបំរើផលប្រយោជន៍ផ្ទាល់ខ្លួនជាច្រើនកន្លែងបណ្ដាលឱ្យសហគមន៍ខ្មែរនៅឡូវែលនេះទន់ខ្សោយជាយូរយាមកហើយ ។ ក្នុងសប្ដាហ៍បន្ទាប់ពីព្រឹត្តិកាណ៍ទប់ស្កាត់ទស្សនៈកិច្ច ហ៊ុន ម៉ាណែត មកទាំងពលរដ្ឋក្នុងសហគមន៍ទាំងក្រុមអ្នកដឹកនាំខ្មែរទាំងអភិបាលក្រុងកំពុងស្វែងរកយល់ពីវត្ថុបំណងពិតប្រាកដរបស់សហគមន៍ខ្មែរនៅឡូវែលដែលគេយល់ថា ទំនងជាមានការយល់ឃើញថា ពីពេលមុនអាចមានការភ័ណ្ឌច្រឡំ។

បាតុកម្មដែលមាន២ក្រុមប្រឈមមុខគ្នានេះប្រាកដជាមិនមែនជាការចងគំនុំនឹងខ្មែរគ្នាឯងទេ តែជាកិច្ចការពារសហគមន៍ដែលសម្បូរមនុស្សមកបោកប្រាស់យកចំណេញសម្រាប់តែផលប្រយោជន៍ខ្លួនឯង ។ អ្នកការពារគណបក្សប្រជាជនគួរតែយល់ថា ការពារនយោបាយដែលកំពុងអនុវត្តិន៍នៅភ្នំពេញ គឺការឱ្យគំរូ "គ្មានសីលធម៌" ដ៏អាក្រក់បំផុត បង្ហាញដល់បណ្ដាកូនចៅនៅទីនេះ ជាពិសេសនៅពេលដែលអ្នកនោះចង់ដើរតួជាដំណាងរបស់ពលរដ្ឋ ។ សាលាក្រុងបានធ្វើសេចក្ដីសម្រេចចិត្តយ៉ាងក្លាហាន ដើម្បីការពារសហគមន៍ខ្មែរនៅឡូវែលពីការបែកបាក់ពីភាពរងគ្រោះ គឺជាការស្រាយចំណងបញ្ហាដំបូងគេនៅពេលដែលពលរដ្ឋខ្មែរ-អាមេរិកាំងភាគច្រើនយល់ថា សាលាក្រុងបានចេញមុខធ្វើឱ្យពួកខ្លួនសប្បាយចិត្ត ៕